00283279

A190/I/20


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE


**តាមនាមប្រជារាស្ត្រខ្មែរ និងតាមនាមអង្គការសហប្រជាជាតិ និងអនុលោមតាមច្បាប់ស្តីពី ការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ**

| | |
|---|---|
| **សំណុំរឿងព្រហ្មទណ្ឌលេខ:** | ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១) |
| **ចំពោះមុខ:** | ចៅក្រម ប្រាក់ គឹមសាន ប្រធាន<br>ចៅក្រម Rowan DOWNING<br>ចៅក្រម នេ៎យ ថុល<br>ចៅក្រម Katinka LAHUIS<br>ចៅក្រម ហួត វុទ្ធី |
| **ក្រឡាបញ្ជី** | ដួន សុរាសី<br>Anne-Marie BURNS |
| **កាលបរិច្ឆេទ:** | ២០ កុម្ភៈ ២០០៩ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 20 / 02 / 2009
ម៉ោង (Time/Heure): 15:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

**សាធារណៈ:**

**សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពី សិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ**

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
យ៉េត ចរិយា
William SMITH
ពេជ្រ សម្បត្តិ
Vincent de WILD d'ESTMAEL
Anees AHMED

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡូ ជុនធី
នី ចាន់ឌី
គង់ ពិសី
យុង ផានិត
គឹម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUZINSKY
Martine JACQUIN
Philippe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE

**សហមេធាវីការពារក្តី**

ស សុវាន
Jacques VERGÉS

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 20 / 02 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fuy

00283280

A190/I/20

០០២/១៨-០៩-២០០៧-អវតក/កសចស (អបជ១១)

**អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក"** បានទទួល "បណ្តឹងឧទ្ធរណ៍របស់ក្រុមមេធាវីការពារក្តី ប្រឆាំងនឹងការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក **ខៀវ សំផន** ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ("បណ្តឹងឧទ្ធរណ៍")។

## ជំពូក ១ - សាវតា

១. អង្គបុរេជំនុំជម្រះ យោងទៅលើរបាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង អនុម័តកាលពីថ្ងៃទី២ ខែធ្នូ ឆ្នាំ២០០៨ លើនីតិវិធីអង្គច្បាប់ និងអង្គហេតុក្នុងសំណុំរឿងនេះ ដែលជាផ្នែកមួយនៃសាលដីកានេះ។

២. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាសម្រេចមួយស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ("ដីកាស្តីពីការបកប្រែ")។ ដីកានេះ បានជូនដំណឹងដល់ភាគីទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២/១៨-០៩-២០០៧-អវតក/កសចស ដោយរួមទាំងជនត្រូវចោទផងដែរ[១]។

៣. នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចស្តីពីការបកប្រែ[២] និងសារណាបណ្តឹងឧទ្ធរណ៍ នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨[៣]។

៤. នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ សហព្រះរាជអាជ្ញាបានដាក់ "ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ **ខៀវ សំផន** ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" ("ចម្លើយតប")[៤]។ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាបានស្នើ

---

[១] ដីកាសម្រេចស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ A190 ("ដីកាស្តីពីការបកប្រែ")។

[២] សៀវភៅចុះបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ A190/I។

[៣] សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ចំពោះការបដិសេធសំណើសុំបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ A190/I/1 ("សារណាបណ្តឹងឧទ្ធរណ៍")។

[៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ A190/I/4 ("ចម្លើយតប")។

00283281

A190/I/20

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១)

សុំឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេចលើបណ្ដឹងឧទ្ធរណ៍ ដោយផ្អែកលើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ។ សហព្រះរាជអាជ្ញាក៏បានស្នើផងដែរថា បណ្ដឹងឧទ្ធរណ៍នេះគួរតែសម្រេចរួមគ្នាជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់លោក **អៀង សារី** ដែលបានប្ដឹងចំពោះដីកាស្ដីពីការបកប្រែផងដែរ[៥] ពីព្រោះ "បណ្ដឹងឧទ្ធរណ៍ទាំងពីរនេះលើកអង្គហេតុ និងអង្គច្បាប់ស្រដៀងគ្នា"[៦]។

៥. សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មិនបានដាក់សេចក្ដីសន្និដ្ឋានតបឡើយ។

៦. នៅថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានទទួលយក "ពាក្យសុំឱ្យមានសវនាការជាសាធារណៈស្ដីពីបណ្ដឹងឧទ្ធរណ៍ ប្រឆាំងនឹងការបដិសេធការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក **ខៀវ សំផន** ដែលសហមេធាវីការពារក្ដីបានដាក់ជូន ហើយអង្គបុរេជំនុំជម្រះបានកំណត់បើកសវនាការនៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៨។[៧] អង្គបុរជំនុំជម្រះបានចេញដីកាកែប្រែកាលបរិច្ឆេទសវនាការជាសាធារណៈ តាមសំណើសុំរបស់សហមេធាវីការពារក្ដីអន្តរជាតិ ដោយកំណត់យកថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ ជាថ្ងៃសវនាការជំនួសវិញ។[៨]

៧. នៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨, សហព្រះរាជអាជ្ញាបានដាក់"សំណើរបស់សហព្រះរាជអាជ្ញាដាក់ឈុតវីដេអូខ្លីៗទៅក្នុងសំណុំរឿង" ("សំណើ")[៩]។ នៅក្នុងសំណើនោះ, សហព្រះរាជអាជ្ញាបានចង្អុលបញ្ជាក់ថា ឈុតវីដេអូខ្លីៗនេះ ខាងមេធាវីការពារក្ដីអាចរកមើលបាន នៅក្នុងកន្លែងតម្កល់ឯកសាររួមគ្នាដែលរក្សាទុកដោយផ្នែកគ្រប់គ្រងតុលាការ។ ដោយពិចារណាឃើញថាឈុតវីដេអូនេះ បានដាក់មួយថ្ងៃមុនថ្ងៃសវនាការ ហើយសហមេធាវីការពារក្ដី អាចរកមើលបាន និងមានលទ្ធភាពដាក់សេចក្ដីសង្កេតរបស់ខ្លួនចំពោះសំណើនេះ និង/ឬ ចំពោះឈុតវីដេអូ

---

[៥] បណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស ស្ដីពីសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ A190/II/1។

[៦] ចម្លើយតប វាក្យខណ្ឌទី ៥។

[៧] សេចក្ដីសម្រេចលើពាក្យសុំឱ្យមានសវនាការជាសាធារណៈ ចុះថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០០៨ A190/I/8។

[៨] ដីកាកែប្រែកាលបរិច្ឆេទសវនាការជាសាធារណៈ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ A190/I/10។

[៩] សំណើរបស់សហព្រះរាជអាជ្ញាដាក់ឈុតវីដេអូខ្លីៗទៅក្នុងសំណុំរឿង ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៨ A190/I/15។



អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC

A190/I/20



នេះ, ដូច្នេះ អង្គបុរេជំនុំជម្រះ ទទួលយកសំណើនេះ ហើយសម្រេចដាក់ឈ្មោះឯកសារទាំងនេះ ហើយសម្រេចដាក់ឯកសារថ្មីៗទៅក្នុងសំណុំរឿង។

៨. មុនថ្ងៃសវនាការ អង្គបុរេជំនុំជម្រះបានទទួលសំណុំរឿង ដែលត្រូវបានធ្វើបច្ចុប្បន្នភាពរួច។

៩. នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបើកសវនាការជាសាធារណៈ។

១០. នៅពេលចាប់ផ្ដើមសវនាការ, លោកស្រី Silke STUDZINSKY សហមេធាវីមួយរូបដែលតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានដាក់សំណើសុំធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់នៅក្នុងពេលសវនាការ។ តាមសេចក្ដីសម្រេចដែលធ្វើឡើងដោយផ្ទាល់មាត់, អង្គបុរេជំនុំជម្រះ បានបដិសេធចោលសំណើសុំនេះ ដោយសម្អាងថា ទោះបីជាសហមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានឱកាសក្នុងការធ្វើសេចក្ដីសន្និដ្ឋានក៏ដោយ ក៏ខ្លួននៅមុនពេលសវនាការពុំបានបង្ហាញអំពីបំណងជាផ្លូវការណាមួយ ក្នុងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ក្នុងពេលសវនាការឡើយ ហើយក៏ពុំបានផ្ដល់នូវការជូនដំណឹងគ្រប់គ្រាន់អំពីលក្ខណៈនៃសេចក្ដីសន្និដ្ឋានរបស់ខ្លួន ផងដែរ។ សេចក្ដីសម្រេចនេះបានចេញផ្សាយជាលាយលក្ខណ៍អក្សរដោយអង្គបុរេជំនុំជម្រះ នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០០៨។[១០]

១១. អង្គបុរេជំនុំជម្រះ បដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញា ដែលស្នើសុំឱ្យសម្រេចបណ្ដឹងឧទ្ធរណ៍នេះ រួមជាមួយនឹងបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ **អៀង សារី** ដែលបានប្ដឹងចំពោះដីកាស្ដីពីការបកប្រែ ពីព្រោះទឡ្ហីករណ៍ទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ទាំងពីរនេះ មានលក្ខណៈខុសគ្នា ហើយភាគីទាំងឡាយមិនអាចឆ្លើយតបទៅនឹងទឡ្ហីករណ៍ទាំងនេះបាន។

---

[១០] សេចក្ដីសម្រេចជាលាយលក្ខអក្សរលើសំណើដោយផ្ទាល់មាត់របស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងនឹងការធ្វើសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ ចុះថ្ងៃទី ៤ ធ្នូ ២០០៨, A190/I/16។

## ជំពូក ២ - ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

១២. នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេច ស្តីពីការបកប្រែ ហើយបានជូនដំណឹងដល់ភាគីទាំងឡាយ នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨។ សហមេធាវីការពារក្តីជនត្រូវចោទ បានដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ អនុលោមតាមវិធាន ៧៥ នៃវិធានផ្ទៃក្នុង។ សារណាបណ្តឹងឧទ្ធរណ៍ បានដាក់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០៨ ហេតុដូច្នេះហើយ សារណាបណ្តឹងឧទ្ធរណ៍នេះ បានដាក់ទាន់កាលបរិច្ឆេទកំណត់។

## ក. សេចក្តីសន្និដ្ឋានរបស់ភាគី

១៣. សហមេធាវីការពារក្តីជនត្រូវចោទ ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ (១) ទុកជាមោឃៈនូវការបដិសេធនៃការស្នើសុំឱ្យមានការបកប្រែនៃសំណុំរឿងព្រហ្មទណ្ឌរបស់លោក **ខៀវ សំផន** (២) កត់សម្គាល់នូវការរំលោភសិទ្ធិនានារបស់ជនត្រូវចោទ ដែលបណ្តាលមកពីអវត្តមាននៃការបកប្រែ។ (៣) បង្គាប់ឱ្យដោះលែងលោក **ខៀវ សំផន** ភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។[១១] សហមេធាវីការពារក្តីជនត្រូវចោទ បានផ្អែកលើមូលដ្ឋានថា សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ពុំមានមូលដ្ឋានផ្លូវច្បាប់ ហើយសិទ្ធិនានារបស់ជន ត្រូវចោទត្រូវបានរំលោភ រហូតដល់ត្រឹមកម្រិតមួយ ដែលមិនអាចធានានូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌លើជនត្រូវចោទ។[១២]

១៤. ពិសេសជាងនេះទៅទៀត សហមេធាវីការពារក្តីជនត្រូវចោទផ្តល់ទឡ្ហីករណ៍ថា ដីកាស្តីពីការបកប្រែ រំលោភលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានជំនួយផ្លូវច្បាប់, សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី, សិទ្ធិទទួលបានសមភាពរវាងគូភាគីក្តី, សិទ្ធិទទួលបានពេលវេលា និងលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំការការពារក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្នុង

---

[១១] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៨០។

[១២] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៧៥-៧៦។

ពេលមួយសមស្រប។[១៣] សហមេធាវីការពារក្តីជនត្រូវចោទសង្កត់ធ្ងន់ផងដែរថា ដីកាសម្រេចស្តីពីការបកប្រែ រំលោភសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានជំនួយផ្លូវច្បាប់ប្រកបដោយប្រសិទ្ធិភាព ដោយសារដីកានេះសម្រេចនេះ មិនបកប្រែសំណុំរឿងទាំងមូលទៅជាភាសាមួយដែលសហមេធាវីការពារក្តីអន្តរជាតិរបស់ជនត្រូវចោទយល់បាន។

១៥. នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន សហមេធាវីការពារក្តីជនត្រូវចោទសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍នេះ បានធ្វើឡើងស្របទៅតាមវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុង។[១៤]

១៦. សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ មិនអាចទទួលយកបានឡើយ ពីព្រោះ៖ “វិធាន ៧៤(៣) បានរៀបរាប់ទាំងអស់នូវប្រភេទដីកាដែលបើកផ្លូវឱ្យជនត្រូវចោទប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ វិធាននេះ មិនបានគិតទុកជាមុនអំពីបណ្តឹងឧទ្ធរណ៍ណាមួយ ប្រឆាំងនឹងដីកាបដិសេធសំណើសុំការបកប្រែឯកសារទៅជាភាសារបស់ជនត្រូវចោទ ឬរបស់មេធាវីការពារក្តីរបស់ខ្លួននោះឡើយ។”[១៥] សហព្រះរាជអាជ្ញាផ្តល់ទឡ្ហីករណ៍តបថា ទោះបីជាបញ្ហាបកប្រែស្ថិតនៅក្រោមអំណាចនៃការធ្វើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក៏ដោយ, សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើបញ្ហានេះ មិនបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ឡើយ។ សហព្រះរាជអាជ្ញាបន្ថែមទៀតថា ការបកប្រែគឺជាកិច្ចការរបស់រដ្ឋបាលតុលាការ ហើយវាហួសពីវិសាលភាពនៃវិធាន ៧៤(៣)។[១៦]

១៧. សហព្រះរាជអាជ្ញាសន្និដ្ឋានបន្តទៀតថា ដីកាសម្រេចស្តីពីការបកប្រែ ពុំប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទឡើយ៖

> “ការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ ដែលតម្រូវឱ្យផ្តល់ឯកសារជាភាសា ដែលចុងចោទអាចយល់បាននោះ គឺត្រឹមត្រូវបានបំពេញឱ្យបានគ្រប់គ្រាន់ដោយដំណោះស្រាយ ចំពោះ

---

[១៣] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៥៦-៧១។

[១៤] សារណាបណ្តឹងឧទ្ធរណ៍ វាក្យខណ្ឌទី ៨។

[១៥] ចម្លើយតប វាក្យខណ្ឌទី ២៦។

[១៦] ចម្លើយតប វាក្យខណ្ឌទី ២៩។

សមត្ថភាពពេញលេញខាងភាសាសាស្ត្ររបស់ក្រុមមេធាវីការពារក្ដី ចំពោះធនធានរបស់ផ្នែកគាំពារការការពារក្ដី ចំពោះអ្នកបកប្រែសរសេរធ្វើការពេញម៉ោង ដែលត្រូវបានចាត់តាំង ដូចនៅក្នុង [សេចក្ដីសម្រេច] ទាក់ទងនឹងការបកប្រែភាសា និងចំពោះការខិតខំប្រឹងប្រែងរបស់ផ្នែកគ្រប់គ្រងតុលាការ ដើម្បីផ្ដល់ជូននូវសេវាបកប្រែឯកសារឱ្យបានទាន់ពេលវេលា។"[១៧]

## ខ. យុត្តាធិការរបស់អង្គបុរេជំនុំជម្រះ

១៨. វិធាន ៧៣ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ៧៣: យុត្តាធិការបន្ថែមរបស់អង្គបុរេជំនុំជម្រះ៖**

បន្ថែមពីលើអំណាចវិនិច្ឆ័យសេចក្ដីលើការខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា ឬ រវាងសហចៅក្រមស៊ើបអង្កេត ដូចមានចែងក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្ដីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ មានតែអង្គបុរេជំនុំជម្រះប៉ុណ្ណោះ ដែលត្រូវមានសមត្ថកិច្ចដើម្បីពិនិត្យលើ៖

ក- បណ្ដឹងឧទ្ធរណ៍ដែលធ្វើឡើងប្រឆាំងទៅនឹងសេចក្ដីសម្រេច និង កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេតដូចមានចែងនៅក្នុងវិធាន ៧៤ ។

ខ- ពាក្យសុំមោឃៈភាពនៃកិច្ចស៊ើបសួរណាមួយ ដូចមានចែងនៅក្នុងវិធាន ៧៦ និង

គ- បណ្ដឹងឧទ្ធរណ៍ផ្សេងៗទៀត ដែលមានចែងនៅក្នុងវិធាន ១១-៥ និង ១១-៦ វិធាន ២៣-៧ និង ២៣-៩ វិធាន ៣៥-៦ និង វិធាន ៣៨-៣ នៃ[វិធានផ្ទៃក្នុងនេះ]។

១៩. នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ វិធាន ៧៤ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ៧៤: មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ**

១. គ្មានបណ្ដឹងឧទ្ធរណ៍ណាមួយត្រូវធ្វើឡើងប្រឆាំងនឹងសេចក្ដីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតបានឡើយ ប្រសិនបើបណ្ដឹងនេះត្រូវបានពិនិត្យ និង សម្រេចរួចហើយ ដោយអង្គបុរេជំនុំជម្រះ ដោយអនុលោមតាមការដោះស្រាយភាពខ្វែងយោបល់គ្នាដែលមានចែងនៅក្នុងវិធាន ៧២។

២. សហព្រះរាជអាជ្ញាអាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងគ្រប់ដីការបស់សហចៅ

---

[១៧] ចម្លើយតប វាក្យខណ្ឌទី ៣៩។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

00283286



ក្រុមស៊ើបអង្កេត។

៣. ជនត្រូវចោទអាចធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ដូចខាងក្រោម ៖

ក- ការបញ្ជាក់ពីយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

ខ- ការបដិសេធពាក្យសុំឱ្យមានកិច្ចស៊ើបសួរណាមួយដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

គ- ការបដិសេធពាក្យសុំឱ្យប្រគល់មកវិញនូវវត្ថុដែលចាប់យក។

ឃ- ការបដិសេធពាក្យសុំរបាយការណ៍របស់អ្នកជំនាញ ដែលអនុញ្ញាតក្រោមវិធានផ្ទៃក្នុង។

ង- ការបដិសេធពាក្យសុំធ្វើកិច្ចស៊ើបសួរបន្ថែមណាមួយដោយអ្នកជំនាញដែលអនុញ្ញាតក្រោមវិធាននេះ។

ច- ពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ឬ ការត្រួតពិនិត្យតាមផ្លូវតុលាការ។

ឆ- ការបដិសេធពាក្យសុំឱ្យប្តឹងទៅអង្គបុរេជំនុំជម្រះដើម្បីមោឃៈភាពកិច្ចស៊ើបសួរណាមួយ។ ឬ

ជ- ទាក់ទងទៅនឹងវិធានការការពារ។"

២០. ដោយសារបណ្តឹងឧទ្ធរណ៍នេះយកវិធាន ៧៤(៣)(ខ) មកធ្វើជាមូលដ្ឋានសម្អាង, ដូច្នេះ អង្គបុរេជំនុំជម្រះត្រូវសម្រេចថាតើ វិធានផ្ទៃក្នុងបើកផ្លូវឱ្យបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត "ដែលសម្រេចបដិសេធ [សំណើ] សុំបំពេញកិច្ចស៊ើបសួរ" បែបនេះដែរឬទេ។

## សំណើសុំបំពេញកិច្ចស៊ើបសួរ ដែលដាក់ជូនដោយជនត្រូវចោទ

២១. វិធាន ៥៥(១០) នៃវិធានផ្ទៃក្នុង ផ្តល់សិទ្ធិឱ្យជនត្រូវចោទស្នើសុំបំពេញកិច្ចស៊ើបសួរ៖

> "នៅគ្រប់ពេលវេលានៃការស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី អាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ដល់ការស៊ើបសួរ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកា បដិសេធឱ្យបានឆាប់

00283287



បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី។ ដីកាបដិសេធនេះបើកផ្លូវប្ដឹងឧទ្ធរណ៍។"

២២. វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុងចែងបន្តទៀតថា៖

> "ក្នុងអំឡុងពេលស៊ើបសួរ ជនត្រូវចោទអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតសួរចម្លើយខ្លួន ស្ដាប់ចម្លើយសាក្សី ចុះទៅដល់ទីកន្លែងកើតហេតុ បង្គាប់ឱ្យធ្វើកោសល្យវិច័យ ឬប្រមូលយកភស្ដុតាងដទៃទៀត។ សំណើនេះត្រូវធ្វើជាលាយលក្ខអក្សរដោយមានបញ្ជាក់មូលហេតុពិតប្រាកដ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រមតាមសំណើនេះទេ សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាម ដែលអាចធ្វើទៅបាន និងនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកាបដិសេធនេះនៅមុនពេលបញ្ចប់កិច្ចស៊ើបសួរ។ ដីកាបដិសេធត្រូវមានសំអាងហេតុ។ ជនត្រូវចោទ ត្រូវបានជូនដំណឹងជាបន្ទាន់អំពីដីកាបដិ-សេធនេះ។ ជនត្រូវចោទ អាចធ្វើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកានេះទៅអង្គបុរេជំនុំជម្រះ។"

២៣. វិធានផ្ទៃក្នុងមិនបានកំណត់អត្ថន័យពាក្យ "កិច្ចស៊ើបសួរ" ឱ្យបានច្បាស់លាស់ទេ។ ប៉ុន្តែ អត្ថន័យនៃពាក្យនេះ អាចធ្វើការសន្និដ្ឋានយល់បាន នៅពេលយើងអានបទប្បញ្ញត្តិផ្សេងៗ នៃវិធានផ្ទៃក្នុងរួមគ្នា។

២៤. នៅក្នុងករណីនេះ វិធាន ៥៥(៥) នៃវិធានផ្ទៃក្នុងចែងថា៖

> "ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត ដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេតត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ។ [...]" (គូសបញ្ជាក់បន្ថែម)

២៥. អង្គបុរេជំនុំជម្រះពិចារណាឃើញថា ដំណើរការលាតត្រដាងការពិត ចាំបាច់ត្រូវពាក់ព័ន្ធនឹងការប្រមូលព័ត៌មាន។ នៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ការប្រមូលភស្តុតាងជាការពិតណាស់ គឺជាគោលបំណងនៃកិច្ចស៊ើបសួរ។[១៨] នៅក្នុងប្រព័ន្ធច្បាប់បារាំង កិច្ចស៊ើបសួរ គឺជាកិច្ចទាំងឡាយ

---

[១៨] Pierre Chambon and Christian Guéry, *Droit et pratique de l'instruction préparatoire*, Dalloz: 2008, p. 6.



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE E.C.C.C. C.E.T.C.

ណា ដែលចៅក្រមស៊ើបអង្កេតបានធ្វើឡើងដើម្បីស្វែងរកភស្តុតាង។[១៩] អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា ប្រព័ន្ធច្បាប់ព្រះរាជាណាចក្រកម្ពុជា ដែលវិធានផ្ទៃក្នុងយកមកធ្វើជាមូលដ្ឋានសម្អាងនោះ គឺវាស្រដៀងនឹងប្រព័ន្ធច្បាប់បារាំង។

២៦. អង្គបុរេជំនុំជម្រះសង្កេតឃើញថា វិធាន ៥៨(៦) នៃវិធានផ្ទៃក្នុង រៀបរាប់ជាក់លាក់អំពីសំណើទាំងឡាយ ដែលជនត្រូវចោទអាចស្នើទៅសហចៅក្រមស៊ើបអង្កេត។ វិធាននេះ សំដៅលើតែកិច្ចទាំងឡាយណា ដែលធ្វើឡើងដើម្បីជាគោលបំណងនៃការប្រមូលភស្តុតាងប៉ុណ្ណោះ ។

២៧. ការចង្អុលបង្ហាញមួយទៀតដែលកិច្ចស៊ើបសួរធ្វើឡើងដើម្បីប្រមូលភស្តុតាង អាចកត់សម្គាល់ឃើញនៅក្នុងវិធាន ៦២ នៃវិធានផ្ទៃក្នុង។ វិធានមួយនេះ ចែងអំពីលទ្ធភាពដែលសហចៅក្រមស៊ើបអង្កេត អាចធ្វើប្រតិភូកម្មអំណាចរបស់ខ្លួនទៅអ្នកស៊ើបអង្កេតរបស់ អ.វ.ត.ក. ឬ មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបំពេញកិច្ចស៊ើបសួរ។ នៅក្នុងវិធានច្បាប់ដែលពាក់ព័ន្ធ, វិធាន ៦២ នៃវិធានផ្ទៃក្នុង ចែងថា៖

> "១. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាចាត់ឲ្យស៊ើបសួរជំនួសទៅឲ្យអ្នកស៊ើបអង្កេតនៃការិយាល័យរបស់ខ្លួន ឬនគរបាលយុត្តិធម៌ដើម្បីបំពេញកិច្ចស៊ើបសួរ។ ប៉ុន្តែមានតែនគរបាលយុត្តិធម៌ទេ ដែលមានអំណាចក្នុងការអនុវត្តន៍វិធានការចាប់បង្ខំ។
>
> ២. ដីកាចាត់ឲ្យស៊ើបសួរជំនួស មិនត្រូវសរសេរជាទម្រង់ទូទៅឡើយ តែត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើការស៊ើបសួរ និងដែលមានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹងបទល្មើសណាមួយ ឬជាមួយនឹងបទល្មើសដែលកំពុងស៊ើបសួរ។ [...]
>
> ៣. អ្នកទទួលការចាត់តាំងត្រូវធ្វើការងារ ក្រោមការដឹកនាំរបស់សហចៅក្រមស៊ើបអង្កេត និងត្រូវរាយការណ៍ជូនទៅសហចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ អំពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស។ នៅពេលដែលដីកាចាត់ឲ្យស៊ើបសួរជំនួស ត្រូវបានប្រគល់ឲ្យទៅអ្នកស៊ើបអង្កេតរបស់អង្គជំនុំជម្រះវិសាមញ្ញ ឬ នគរបាលយុត្តិធម៌ ជននោះត្រូវអនុវត្តដូចខាងក្រោម:
>
> ក- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេត ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស៊ើបសួរ និងលទ្ធផលនៃការស៊ើបសួររបស់ខ្លួន ដោយអនុលោម

[១៩] Jean Pradel, *Manuel de Procédure Pénale*, Cujas: 2000, para. 723: *"Positivement, les actes d'instruction sont tous les actes des recherche des preuves accomplis par le juge d'instruction et tous ceux qui ont été accomplis au cours de l'enquête de police [illegible] qu'ils font partie de la procédure d'instruction."*

តាមបញ្ញត្តិនៃវិធាន ៥១-៨ តាមករណីសមស្រប។

ខ- នគរបាលយុត្តិធម៌ ឬអ្នកស៊ើបអង្កេតមិនត្រូវសួរចម្លើយជនត្រូវចោទឡើយ។ អ្នកស៊ើបអង្កេតអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមអនុវិធាន ៥៩(៦)។

គ- នគរបាលយុត្តិធម៌ អាចឆែកឆេរ និងចាប់យកភស្តុតាងបាន ដោយមានការអនុញ្ញាតពីសហចៅក្រមស៊ើបអង្កេត។

[...]”

២៨. ផ្អែកលើសេចក្តីពិចារណាទាំងនេះ អង្គបុរេជំនុំជម្រះយល់ឃើញថា សំណើសុំបំពេញកិច្ចស៊ើបសួរ គួរត្រូវគេបកស្រាយថា ជាសំណើសុំឱ្យសហចៅក្រមស៊ើបអង្កេត ឬ អ្នកស៊ើបអង្កេត ឬក៏មន្ត្រីនគរបាលយុត្តិធម៌ តាមរយៈដីកាចាត់ឱ្យសួរជំនួស បំពេញកិច្ចណាមួយ ក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត។

## ដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ

២៩. ដីកាស្តីពីការបកប្រែ កំណត់សិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ។ ពាក់ព័ន្ធនឹងដីកានេះ សហចៅក្រមស៊ើបអង្កេត បានលើកឡើងថា៖

> “យល់ឃើញពីភាពខ្វះចន្លោះនៃបទប្បញ្ញត្តិ ស្តីពីវិសាលភាពនៃសិទ្ធិ និងកាតព្វកិច្ចពាក់ព័ន្ធនឹងការបកប្រែ យល់ឃើញថា ខ្លឹមសារនៃសិទ្ធិ និងកាតព្វកិច្ចនេះ គឺជាបញ្ហាសំខាន់ដែលទាក់ទងទៅនឹងផលប្រយោជន៍ទូទៅ ដូច្នេះសហចៅក្រមស៊ើបអង្កេត បានសម្រេចចេញអនុស្សរណៈនេះទៅគ្រប់ភាគីទាំងអស់”[២០]

៣០. ដីកាស្តីពីការបកប្រែ ពុំបង្កើតជាកិច្ចមួយ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីប្រមូលព័ត៌មានឡើយ។ បន្ថែមពីនេះទៀត គេកត់សម្គាល់ឃើញថា សហចៅក្រមស៊ើបអង្កេត មិនទទួលបានសំណើសុំឱ្យបំពេញកិច្ចណាមួយ ដែលជាលក្ខខណ្ឌមួយនៃការបំពេញកិច្ចស៊ើបសួរ ដូចដែលបានលើកឡើងខាងលើឡើយ។[២១]

---

[២០] ដីកាស្តីពីការបកប្រែ ទំព័រទី ២។

[២១] កំណត់ហេតុនៃការសួរចម្លើយ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ D75 ទំព័រទី ២។

៣១. អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ មិនបានប្តឹងប្រឆាំងចំពោះដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរឡើយ។ ដូច្នេះ បណ្តឹងឧទ្ធរណ៍នេះ មិនស្ថិតនៅក្នុងវង្វង់នៃកម្មវត្ថុនានា ដែលបើកផ្លូវឱ្យប្តឹងឧទ្ធរណ៍ ដូចមានចែងនៅក្នុងវិធាន ៧៤(៣)(ខ) នៃវិធានផ្ទៃក្នុងនោះទេ។

៣២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញទៀតថា មិនមានបទប្បញ្ញត្តិណាផ្សេងដាក់លាក់នៅក្នុងវិធានផ្ទៃក្នុង ដែលបើកផ្លូវឱ្យជនត្រូវចោទប្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេច ស្តីពីការបកប្រែ នៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ។

៣៣. វិធានផ្ទៃក្នុងចែងអំពីដីកាមួយចំនួន ដែលបើកផ្លូវឱ្យជនត្រូវចោទប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដីកាទាំងនេះ មានចែងគ្រប់ទាំងអស់ ហើយអង្គបុរេជំនុំជម្រះមានយុត្តាធិការសម្រេចលើបណ្តឹងឧទ្ធរណ៍ចំពោះដីកា និងសេចក្តីសម្រេចទាំងឡាយណា ដែលបានលើកឡើងនៅក្នុងនោះតែប៉ុណ្ណោះ។ ដីកាសម្រេចដទៃទៀតរបស់សហចៅក្រមស៊ើបអង្កេត ស្ថិតនៅក្រោមការត្រួតពិនិត្យ តាមរយៈនីតិវិធីមោឃភាព ដែលនីតិវិធីនេះអនុញ្ញាតឱ្យជនត្រូវចោទស្នើសុំឱ្យតុលាការ មោឃៈនីតិវិធីណាមួយដែលមានវិការៈ ជាហេតុនាំឱ្យមានការរំលោភលើសិទ្ធិរបស់ខ្លួន។[២២] អង្គបុរេជំនុំជម្រះសង្កេតឃើញថា នីតិវិធីនេះមានលក្ខណៈខុសគ្នាពីនីតិវិធីប្តឹងឧទ្ធរណ៍ ហេតុដូចនេះសហមេធាវីការពារក្តីត្រូវមានចំណាត់ការផ្សេងគ្នា ក្នុងការលើកយកបញ្ហាមកចំពោះមុខអង្គបុរេជំនុំជម្រះ។

## សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

៣៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សហមេធាវីការពារក្តីធ្វើការចោទប្រកាន់ថា ដីកាសម្រេចស្តីពីការបកប្រែ បានរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ដូចបានពន្យល់នៅក្នុងវាក្យខណ្ឌទី ១៤ ខាងលើ។

---

[២២] វិធាន ៧៦(៤) *ទត្ថ្ករណ៍* និងវិធាន ៤៨ នៃវិធានផ្ទៃក្នុង។



PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE ECCC * CETC

៣៥. ចំពោះករណីនេះ វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា៖

**"វិធាន ២១: គោលការណ៍ជាសារវ័ន្ត**

១. ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ញារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង ជនរងគ្រោះ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និង កិច្ចព្រមព្រៀង។ ក្នុងបរិបទនេះ៖

ក- ដំណើរការនីតិវិធីក្នុងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវតែមានយុត្តិធម៌ និង ត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។ [...]

[...]

ឃ- ជនណាដែលត្រូវបានសង្ស័យ ឬ ត្រូវបានចោទប្រកាន់ ត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ។ ជនទាំងនេះមានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលចោទប្រកាន់ចំពោះខ្លួន និង មានមេធាវីការពារតាមការជ្រើសរើសរបស់ខ្លួន ហើយនិងនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីត្រូវផ្តល់ព័ត៌មានដល់គេ អំពីសិទ្ធិនៅស្ងៀមមិនឆ្លើយតប។"

៣៦. អង្គបុរេជំនុំជម្រះនឹងធ្វើការពិនិត្យថាតើវិធាន ២១ នៃវិធានផ្ទៃក្នុងតម្រូវឱ្យធ្វើការបកស្រាយសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ក្នុងន័យទូលាយដែរឬទេ ដើម្បីធានាថា ដំណើរការនីតិវិធីក្នុងពេលស៊ើបសួរ មានភាពយុត្តិធម៌ និងបានគោរពគោលការណ៍ចំពោះមុខ ហើយបានរក្សានូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ។

៣៧. ដីកាសម្រេចស្តីពីការបកប្រែចែងថា ជនត្រូវចោទមានសិទ្ធិទទួលបានការបកប្រែនូវឯកសារដូចខាងក្រោម ទៅជាភាសាបារាំង៖

- ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត
- ភស្តុតាង ដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងយកមកធ្វើជាមូលដ្ឋានសម្រាប់

- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា
- លេខយោង និងតារាងអក្សររៀងនៃអង្គហេតុ ដែលដីកាទាំងនេះសម្អាងលើ (ជាក់ស្តែងគឺឯកសារ D3 និង D3/I-V)
- សេចក្តីសម្រេច និងដីកាទាំងអស់របស់តុលាការ និង
- ឯកសារទាំងអស់ដែលភាគីបានដាក់ជូននៅចំពោះមុខ អ.វ.ត.ក. ដូចមានចែងនៅក្នុងមាត្រា ៧(១) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក។[២៣]

៣៨. យោងតាមដីកាសម្រេចស្តីពីការបកប្រែ ឯកសារទាំងនេះ ត្រូវបកប្រែជាភាសាខ្មែរផងដែរ ដែលជាភាសាកំណើតរបស់ជនត្រូវចោទ។

៣៩. សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា ដីកាសម្រេចនេះ បានធ្វើឡើងក្នុងគោលបំណងកំណត់សិទ្ធិ និងកាតព្វកិច្ចរបស់ភាគីក្នុងអំឡុងកិច្ចស៊ើបសួរ និង "ក្នុងគោលបំណងឱ្យអង្គជំនុំជម្រះសាលាដំបូងនៅពេលដែលទទួលបានសំណុំរឿង រៀបចំចាត់ចែងលើសេចក្តីត្រូវការនៃការបកប្រែសម្រាប់សវនាការនានា ដើម្បីជាប្រយោជន៍ដល់ការគ្រប់គ្រងល្អរបស់តុលាការ និងសិទ្ធិទទួលបាននូវការកាត់សេចក្តីដោយយុត្តិធម៌។"[២៤]

៤០. អង្គបុរេជំនុំជម្រះសង្កេតឃើញថា អនុលោមតាមវិធាន២១(១)(ឃ) នៃវិធានផ្ទៃក្នុង ជនត្រូវចោទ មានសិទ្ធិទទួលដំណឹងអំពីបទល្មើសដែលដាក់បន្ទុកលើខ្លួន។ ប៉ុន្តែ ទាំងច្បាប់ អ.វ.ត.ក. ទាំងវិធានផ្ទៃក្នុង ពុំផ្តល់សិទ្ធិជាក់លាក់បែបនេះដល់ជនត្រូវចោទ ក្នុងការទទួលបានការបកប្រែឯកសារទាំងអស់នៅក្នុងសំណុំរឿង ទៅជាភាសារបស់ជនត្រូវចោទ ឬជាភាសារបស់មេធាវីការពារក្តីខ្លួនឡើយ។ ទោះបីជាភាសានោះ ជាភាសាផ្លូវការមួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់តុលាការ, វាក៏ពុំបង្កើតជាសិទ្ធិឱ្យជនត្រូវចោទ ក្នុងការទទួលបានការបកប្រែឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿងរបស់ខ្លួន ទៅជាភាសានោះឡើយ។

---

[២៣] សេចក្តីណែនាំអនុវត្តស្តីអំពីការដាក់ឯកសារនៅអវតក, អវតក/០១/២០០៧ វិ. លើកទី៣។

[២៤] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ង (៤)។



PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE ECCC CETC

៤១. ស្របជាមួយសម្អាងហេតុនៅក្នុងដីកាស្តីពីការបកប្រែ[២៥] យុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិនានា សម្រេចដដែលៗថា សិទ្ធិរបស់ចុងចោទក្នុងការទទួលបានការបកប្រែឯកសារទៅជាភាសាដែលខ្លួនយល់ ពុំរួមបញ្ចូលគ្រប់ឯកសារទាំងអស់នៅក្នុងសំណុំរឿងរបស់ខ្លួនឡើយ[២៦] ទោះបីជាក្នុងករណីចុងចោទធ្វើជាតំណាងដោយខ្លួនឯងក៏ដោយ។[២៧] ហើយសំណើសុំការបកប្រែសំណុំរឿងទាំងអស់ទៅជាភាសាមេធាវីរបស់ចុងចោទនោះទៀតសោត ក៏ត្រូវបានសាលាក្តីបដិសេធចោលផងដែរ។[២៨] ពិសេសជាងនេះទៅទៀត សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា, សាលាក្តីទាំងពីរនេះបានលើកចោលសំណើសុំបកប្រែឯកសារទាំងអស់។ ការបដិសេធសំណើនេះ គឺដោយផ្អែកលើមូលដ្ឋានថា ការបកប្រែជាមុននូវរាល់ និងគ្រប់ឯកសារទាំងអស់ជាភាសារបស់ជនជាប់ចោទ លើសពីលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងលក្ខន្តិកៈ និងវិធាននានា អាចប៉ះពាល់ធ្ងន់ធ្ងរដល់សិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្នុងពេលមួយឆាប់រហ័ស ពីព្រោះបញ្ហាពេលវេលា និងធនធាន ដែលទាមទារនៅក្នុងការបកប្រែឯកសារទាំងអស់មានទំហំធំធេង។"[២៩] តុលាការព្រហ្មទណ្ឌអន្តរជាតិ បានសម្រេចថា គោលការណ៍យុត្តិធម៌ពុំបាន "ផ្តល់ដល់[ជនត្រូវចោទ]នូវសិទ្ធិទទួលបានការបកប្រែឯកសារទាំងអស់ដែលទាក់ទងនឹងបញ្ហានីតិវិធី និងឯកសារភស្តុតាងទាំងអស់ ដែលដាក់ជូនដោយអយ្យការឡើយ។"

---

[២៥] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ក (២) និង ខ (២)។

[២៦] *Prosecutor v. Lubanga*, ICC-01/04-01/06, "Decision on the Requests of the Defence of 3 and 4 July 2006", Pre-Trial Chamber I, 4 August 2006 ("*Lubanga*"), pp. 5-6; *Prosecutor v. Katanga*, ICC-01/04-01/07, "Decision on Defence for Mathieu Ngudjolo Chui's Request Concerning Translation of Documents", Pre-Trial Chamber I, 15 May 2008, pp. 3 and 5; *Prosecutor v. Chui*, ICC-01/04-02/07, "Decision on the Defense Request Concerning Time Limits", Pre-Trial Chamber I, 27 February 2008, pp. 3-4; *Prosecutor v. Muhimana*, ICTR-95-I-B-I, "Decision on Defence Motion for the Translation of Prosecution and Procedural Documents into Kinyarwanda", Trial Chamber I, 6 November 2001 ("*Muhimana*"), para. 25; *Prosecutor v. Seselj*, IT-03-67-PT, "Order on Translation", Trial Chamber II, 6 March 2003 ("*Seselj*"), p. 1; Prosecutor v. Ljubicic, IT-00-41-PT, "Decision on Defence Counsel's Request for Translation of All Documents", Trial Chamber I, 20 November 2002 ("*Ljubicic*"), p. 3; *Prosecutor v. Naletilic*, IT-98-34-T, "Decision on Defence's Motion Concerning Translation of All Documents", Trial Chamber I, 18 October 2001, p. 3; *Prosecutor v. Delalic*, IT-96-21-T, "Decision on Defence Application for Forwarding the Documents in the Language of the Accused", Trial Chamber, 25 September 1996, para. 8; *Kamasinski v. Austria*, Application No. 9783/82, 19 December 1989 ("*Kamasinski*"), para. 74.

[២៧] See *Seselj*.

[២៨] *Muhimana*, paras 31-33.

[២៩] *Ljubicic*, p. 3; See also *Seselj*, p. 2; *Muhimana*, para. 12.

00283294

A190/I/20



៤២. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា សិទ្ធិរបស់សហមេធាវីការពារក្តីក្នុងការពិនិត្យសំណុំរឿងក្នុងអំឡុងកិច្ចស៊ើបសួរ ពុំមានន័យថា ឯកសារទាំងអស់ដែលប្រមូលបាន គួរត្រូវបកប្រែជាភាសារបស់ពួកគេ ដោយស្វ័យប្រវត្តិនោះទេ។[៣០]

៤៣. ប៉ុន្តែ អង្គបុរេជមនុំជម្រះយល់ឃើញថា ផ្អែកតាមកាលៈទេសៈជាក់លាក់នៃរឿងក្តី ការបកប្រែឯកសារណាមួយ(នានា) អាចជាភាពចាំបាច់ក្នុងការធានាឱ្យជនត្រូវចោទមានលទ្ធភាពអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងអំឡុងកិច្ចស៊ើបសួរ។[៣១] ការសម្រេចថា "លក្ខខណ្ឌសំខាន់គឺ ដើម្បីអនុញ្ញាតឱ្យជនត្រូវចោទមានការយល់ដឹងពីសំណុំរឿងដែលចោទប្រកាន់ខ្លួន និងអាចការពារខ្លួនឯងបានជាពិសេសអាចបកស្រាយអំពីអង្គហេតុជូនតុលាការបាន"[៣២], សហចៅក្រមស៊ើបអង្កេតបានកំណត់បទដ្ឋានមួយដែលត្រូវធានាថា ជនត្រូវចោទអាចអនុវត្តសិទ្ធិនានារបស់ខ្លួន ក្នុងអំឡុងកិច្ចស៊ើបសួរ និងដើម្បីធានាគោលការណ៍យុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅក្នុងដំណាក់ការនេះ។

៤៤. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា តាមអំណាចនៃដីកាស្តីពីការបកប្រែ ជនត្រូវចោទបានទទួលឯកសារដូចខាងក្រោមនេះ ជាភាសាខ្មែរ និងភាសាបារាំង៖

- ដីកាសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ ដោយរួមបញ្ចូលទាំងលេខយោង ដែលរៀបរាប់ឯកសារគាំទ្រការចោទប្រកាន់របស់សហព្រះរាជអាជ្ញា
- សំណុំឯកសារ ដែលភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមមានបញ្ជីពិពណ៌នាអំពីឯកសារភស្តុតាង គាំទ្រដល់ព្រឹត្តការណ៍ ឬឧក្រិដ្ឋកម្មជាក់លាក់ ដែលបានចោទប្រកាន់។

---

[៣០] នេះទំនងជាវិធីសាស្ត្រដែលប្រព័ន្ធច្បាប់ច្បាប់បារាំងយកលំនាំតាម។ See in particular Crim. Cass. 4 October 1995, Bull. crim. no. 293; Jean Pradel, *Manuel de Procédure Pénale*, Cujas: 2000, para. 383.

[៣១] តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្សបានសម្រេចដោយស្របគ្នាថា វិធីសាស្ត្រដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានគេយកមកអនុវត្តនៅក្នុងពេលស៊ើបអង្កេតបឋម "អាស្រ័យលើលក្ខណៈពិសេសនៃដំណើរការក្តីដែលពាក់ព័ន្ធ និងកាលៈទេសៈនៃរឿងក្តី" ហើយ"ដើម្បីសម្រេចថា គោលបំណងនៃមាត្រា ៦ - ការជំនុំជម្រះដោយយុត្តិធម៌ - ទទួលបាន ដែរឬទេ, ដំណើរការក្តីក្រោមច្បាប់ជាតិទាំងមូលដែលគេធ្វើឡើងនៅក្នុងរឿងក្តីត្រូវយកមកពិចារណា"។ See in particular *Imbroscia v. Switzerland,* Application no. 13972/88, 24 November 1993, para. 38. See also *Granger v. the United Kingdom*, Application no. 11932/86, 28 March 1990, para. 44.

[៣២] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ខ(២)។ នេះក៏ជាបទដ្ឋានផងដែរ ដែលអនុវត្តដោយតុលាការព្រហ្មទណ្ឌអន្តរជាតិ និង តុលាការអ៊ឺរ៉ុបផ្នែកសិទ្ធិមនុស្ស។ See in particular *Lubanga*, p. 5 quoting para. 74 of *Kamasinski.*

00283295



- ឧបសម្ព័ន្ធ គ នៃសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលរួមមានបញ្ជីនៃឯកសារទាំងអស់ ដែលជាផ្នែកមួយនៃសំណុំរឿង នៅពេលដាក់សេចក្ដីសន្និដ្ឋានបញ្ជូនរឿងទៅស៊ើបសួរ។ ឧបសម្ព័ន្ធនេះ អមមកជាមួយនូវសេចក្ដីពិពណ៌នាអំពីខ្លឹមសារនៃឯកសារនីមួយៗ។
- បន្ទាប់ពីបើកកិច្ចស៊ើបសួរ ឯកសារភស្តុតាងស្ទើរតែទាំងអស់ ដែលបង្កើតដោយសហចៅក្រមស៊ើបអង្កេត រួមមានភស្តុតាងជាឯកសារ និងកំណត់នៃការសួរយកចម្លើយ (ជាភាសាខ្មែរ និង/ឬ ភាសាបារាំង)។ និង
- ដីកា និងសេចក្ដីសម្រេចទាំងអស់របស់សហចៅក្រមស៊ើបអង្កេត និងអង្គបុរេជំនុំជម្រះ រួមទាំងសេចក្ដីសន្និដ្ឋានរបស់ភាគី ចំពោះបណ្ដឹងឧទ្ធរណ៍របស់ជនត្រូវចោទ។

៤៥. ក្នុងចំណោមឯកសារទាំងឡាយ ដែលសហព្រះរាជអាជ្ញាចង្អុលយោងពាក់ព័ន្ធនឹងការទទួលខុសត្រូវផ្ទាល់របស់ជនត្រូវចោទ មានតែឯកសារមួយចំនួនតិចប៉ុណ្ណោះ ដែលមិនមានជាភាសាខ្មែរ ឬ ភាសាបារាំង។[៣៣]

៤៦. ជនត្រូវចោទ មានមេធាវីជាតិមួយរូប និងមេធាវីអន្តរជាតិមួយរូប ជាតំណាងរបស់ខ្លួនអនុលោមតាមសិទ្ធិ ដូចមានចែងនៅក្នុងវិធាន ២២ នៃវិធានផ្ទៃក្នុង។ សហព្រះរាជអាជ្ញា បានសន្និដ្ឋានថា ក្រុមការពារក្ដីរបស់ជនត្រូវចោទ រួមមានអ្នកប្រឹក្សាផ្នែកច្បាប់មួយរូប ដែលមានសមត្ថភាពផ្នែកភាសាបារាំង និងភាសាអង់គ្លេស[៣៤] និងអ្នកច្បាប់កម្ពុជាមួយរូប ដែលមានសមត្ថភាពផ្នែកភាសាខ្មែរ ភាសាបារាំង និងភាសាអង់គ្លេស។ សេចក្ដីសន្និដ្ឋាននេះ មិនមានការតវ៉ាពីសហមេធាវីការពារក្ដីឡើយ។

---

[៣៣] ក្នុងចំណោមឯកសារដែលយកស្រង់នៅក្នុងលេខយោង ៤០៦ ដល់ ៤៨៤ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលលើកឡើងអំពីទំនួលខុសត្រូវផ្ទាល់ខ្លួនរបស់ជនត្រូវចោទ, មានឯកសារចំនួនតែ ១៣ ច្បាប់ ប៉ុណ្ណោះដែលមិនមានជាភាសាខ្មែរ ឬភាសាបារាំងនៅក្នុងដំណាក់កាលនេះ។ ឯកសារទាំង ១៣ ច្បាប់ នេះសរុបមានចំនួន ១២៩ ទំព័រ។

[៣៤] ចម្លើយតប វាក្យខណ្ឌទី ៣៥។

៤៧. បន្ថែមលើក្រុមការងារច្បាប់របស់ខ្លួន ជនត្រូវចោទត្រូវបានគេអនុញ្ញាត "ឱ្យមានជំនួយពីអ្នកបកប្រែម្នាក់ ដែលបំពេញការងារពេញម៉ោង និងមិនគិតថ្លៃ (ចំពោះភាសាការងារជាផ្លូវការចំនួនពីរ តាមការចង្អុលបញ្ជាក់របស់ក្រុមការពារក្តី) ដើម្បីធានាថា ជនត្រូវចោទ និងក្រុមការពារក្តី អាចទទួលបានការបកប្រែឯកសារជាក់លាក់មួយចំនួនតាមតម្រូវការ ដើម្បីវាយតម្លៃលើតម្រូវការបកប្រែរបស់ក្រុមការពារក្តី ក្នុងការបញ្ជូនមក[ផ្នែកគ្រប់គ្រងតុលាការ] និងដើម្បីជួយដល់ការសហការគ្នារបស់ក្រុមនេះ ជាមួយនឹងផ្នែកគ្រប់គ្រងតុលាការ។"[៣៥] ក្នុងករណីនេះ គេកត់សម្គាល់ឃើញថា យុត្តិសាស្ត្រអន្តរជាតិបានទទួលស្គាល់ថា ការផ្តល់អ្នកបកប្រែផ្ទាល់មាត់មួយរូបដល់ចុងចោទ គឺជាយន្តការជំនួសគ្រប់គ្រាន់ចំពោះការផ្តល់ការបកប្រែលើឯកសារជាក់លាក់មួយចំនួន។[៣៦]

៤៨. ជនត្រូវចោទ ត្រូវបានគេអនុញ្ញាតឱ្យបង្ហាញឯកសារជាក់លាក់ដើម្បីស្នើសុំការបកប្រែសម្រាប់ខ្លួនផងដែរ។[៣៧]

៤៩. អង្គបុរេជំនុំជម្រះកត់សម្គាល់ថា សាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា យល់ឃើញថា ឯកសារដោះបន្ទុក ត្រូវតែផ្តល់ឲ្យចុងចោទជាភាសាមួយដែលគាត់យល់បាន ដើម្បីឲ្យចុងចោទអាចរៀបចំការការពារខ្លួន។ អង្គបុរេជំនុំជម្រះយល់ឃើញថា ក្រុមមេធាវីការពារក្តីមានតួនាទីកំណត់ឲ្យបានត្រឹមត្រូវនូវឯកសារ ដែលអាចយកមកប្រើប្រាស់ជាឯកសារដោះបន្ទុក ហើយបន្ទាប់មកស្នើសុំឲ្យបកប្រែឯកសារពាក់ព័ន្ធទាំងនោះ តាមអំណាចនៃដីកាសម្រេចស្តីពីការបកប្រែ។

៥០. អង្គបុរេជំនុំជម្រះយល់ឃើញថា សិទ្ធិនានារបស់ជនត្រូវចោទ ដូចមានចែងនៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង មិនត្រូវបានគេរំលោភឡើយ។ ដីកាសម្រេចស្តីពីការបកប្រែ គឺធ្វើឡើងដោយស្របតាមបទដ្ឋានអន្តរជាតិចំពោះសិទ្ធិបកប្រែទាំងនេះ។ ការផ្តល់អ្នកបកប្រែមួយរូប

---

[៣៥] ដីកាស្តីពីការបកប្រែ វាក្យខណ្ឌ ង (៣)។

[៣៦] *Kamasinski*, paras 80-81, 85; *Muhimana*, para. 30; *Lubanga*, p. 7.

[៣៧] ដីកាស្តីពីការបកប្រែ ទំព័រទី ៧។

A190/I/20

០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ១១)

សម្រាប់ក្រុមមេធាវីការពារក្តីដែលប្រើច្រើនភាសា គឺដើម្បីធានាថា តម្រូវការចាំបាច់ទាំងអស់ផ្នែកភាសា បានបំពេញសមស្របនៅក្នុងដំណាក់កាលនេះនៅចំពោះមុខ អ.វ.ត.ក។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ២១ នៃវិធានផ្ទៃក្នុង មិនមានអានុភាពចាប់បង្ខំឱ្យធ្វើការបកស្រាយវិធានផ្ទៃក្នុង ក្នុងវិធីមួយដែលនាំឲ្យការប្រកាសទទួលយកបណ្តឹងឧទ្ធរណ៍ចំពោះដីកាស្តីពីការបកប្រែឡើយ។

**ហេតុដូច្នេះ អង្គបុរេជំនុំជម្រះសម្រេចជាឯកច្ឆន្ទៈ:**

មិនទទួលយកបណ្តឹងឧទ្ធរណ៍នេះ។

**ភ្នំពេញ ថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០៨**

**អង្គបុរេជំនុំជម្រះ**

**ប្រធាន**

Rowan DOWNING **ន៉ីយ ថុល** Katinka LAHUIS **ហួត វុធី** **ប្រាក់ គឹមសាន**

**ក្រឡាបញ្ជី**

**ជួន សុរាសី** **Anne Marie BURNS**